# រៀនអក្សរខ្មែរ

## ថ្នាក់ ១




**UNHCR**

KHAO I DANG EDUCATION DEVELOPMENT CENTER

# រៀនអក្សរខ្មែរ

## ថ្នាក់ ១





# UNHCR

## KHAO I DANG EDUCATION DEVELOPMENT CENTER

# អារម្ភកថា

សៀវភៅ "រៀនអក្សរខ្មែរថ្នាក់១" ត្រូវបានបែងចែកជា ៧ ជំពូក ៖
ជំពូក ១: ស្រៈផ្សំនឹងព្យញ្ជនៈ ក-ត
ជំពូក ២: ព្យញ្ជនៈអឃោសៈ
ជំពូក ៣: ព្យញ្ជនៈឃោសៈ
ជំពូក ៤: ប្រកប
ជំពូក ៥: ជើងជើង
ជំពូក ៦: ព្យាង្គតម្រួត
ជំពូក ៧: អត្ថបទ ចំរៀង រឿងកំសាន្ត រឿងព្រេងខ្មែរ ។

ក្នុងជំពូក១ យើងបង្រៀន ស្រៈផ្សំនឹងព្យញ្ជនៈ ព្រោះយើងមានបំណងអោយសិស្សចេះពាក្យជារូបិយ ។ យើងបានចែកស្រៈជាពីរពួកគឺ ស្រៈរាយ និងស្រៈផ្សំ ។ ដំបូងយើងបង្រៀនស្រៈរាយ ។ កាលណាសិស្សចេះស្រៈរាយប្រាកដហើយ សិស្សអាចរៀនស្រៈផ្សំបានរហ័ស ។

ព្យញ្ជនៈណាដែលមានទ្រង់ទ្រាយប្រហែលគ្នា ទើបយកមកបញ្ចូលក្នុងមេរៀនជាមួយ ដើម្បីអោយសិស្សងាយសរសេរ ងាយចាំដូចជា ក និង ត ល និង ឈ ជាដើម ។ ក្រោយពីរៀនព្យញ្ជនៈ យើងបានបញ្ចូលវិធីប្តូរសម្លេងព្យញ្ជនៈដោយប្រើបន្តក់ពីរ និងត្រីស័ព្ទ ។

ចាប់ពីជំពូក១ ដល់ជំពូក៦ យើងរៀន ពាក្យ មួយព្យាង្គខ្លះ ពីរព្យាង្គខ្លះ មានលក្ខណៈជារូបិយព្រមទាំងមាន រូប ជាដំណាង ។ យើងក៏បានបញ្ចូល ឃ្លា ខ្លីៗ រៀបចំតាមភាសាក្មេងផងដែរ ។

នៅក្នុងជំពូក ៧ មាន ៖

ក. អត្ថបទ: អត្ថបទសរសេរឡើងសំរាប់អប់រំចរិយាកុមារអោយមានសណ្ដាប់ធ្នាប់ វិន័យ អនាម័យ ហើយយើងបានបញ្ចូលអត្ថបទខ្លះស្ដីអំពីធនធានធម្មជាតិ ប្រពៃណីខ្មែរ និងវប្បធម៌ខ្មែរផងដែរ ។

ខ. ចំរៀងខ្មែរ: មានលក្ខណៈប្រជាប្រិយសំរាប់កុមារ ។

គ. រឿងកំសាន្ត: មានបំណងអប់រំចិត្តគំនិតក្មេង ដូចជារឿង ដំរីនិង ស្រមោច ដែលពាក់ចិត្តគំនិតក្មេងអោយចេះស្រឡាញ់គ្នានឹងជួយសង្គ្រោះគ្នាទៅវិញទៅមក ។

ឃ. រឿងព្រេងខ្មែរ: ស្របតាមចំណូលចិត្តកុមារតូចៗ អាចបំផុសការឈ្លាសវៃ ដូចជារឿង ធនញ្ជ័យកាលនៅវ័យកុមារ ។

យើងសង្ឃឹមថា សៀវភៅ "រៀនអក្សរខ្មែរថ្នាក់ ១" នឹងក្លាយទៅជាឧបករណ៍សិក្សាសំរាប់រៀនអក្សរនិងភាសាខ្មែរ ប៉ុន្តែយើងជឿថាកិច្ចការរៀបរៀងប្រាកដជាបានបន្សល់ទុកនូវការឆ្គាំឆ្គងនិងកង្វះខាតខ្លះជាមិនខាន ។ យើងរង់ចាំទទួលការរិះគន់ និងយោបល់របស់លោកគ្រូ អ្នកគ្រូ និង អស់លោកអ្នកអានទាំងឡាយយ៉ាងរីករាយបំផុត ដើម្បីសំអិតសំអាង សៀវភៅ "រៀនអក្សរខ្មែរថ្នាក់ ១" នេះអោយរឹតតែមានលក្ខណៈល្អឡើងទៀតនៅពេលបោះពុម្ពលើកក្រោយ ។

ថ្ងៃទី ៩ មីនា ឆ្នាំ ១៩៨០

# មាតិការឿង


| ជំពូក | រឿង | ទំព័រ |
|---|---|---|
| | សេចក្តីថ្លែងអំណរគុណ | |
| | អារម្ភកថា | |
| ជំពូក ១ | ស្រៈផ្សំ និង ព្យញ្ជនៈ ក . ត | 1 |
| ជំពូក ២ | ព្យញ្ជនៈអឃោសៈ | 15 |
| ជំពូក ៣ | ព្យញ្ជនៈឃោសៈ | 23 |
| ជំពូក ៤ | ប្រកប | 37 |
| ជំពូក ៥ | ផ្ញើជើង | 51 |
| ជំពូក៦ | ព្យាង្គតម្រួត | 65 |
| ជំពូក៧ | អត្ថបទ . ចំរៀង . រឿងកំសាន្ត . រឿងព្រេងខ្មែរ | 71 |
| | បន្ថែម | |
| | តារាងអក្សរភ្ជាប់នឹងរូបភាព | |

# ជំពូក១ ស្រៈផ្សំនឹងព្យញ្ជនៈ

## មេរៀន ១: ស្រៈភាយ









# មេរៀន២: ព្យញ្ជនៈទី១

ក

ក ក ក ក

ក ក ក ក

ក ំ កំ

ក ា កា

កំ កំ កំ កំ

កា កា កា

កា






មេរៀន ៣





មេរៀន៤:  ព្យញ្ជនៈទី២

# ត



ត ត ត ត

តំ តំ តំ តំ

តា តា តា

តិ តី តឹ តឺ

តា



# មេរៀន ៥

# ុ ូ ួ

ុ ុ ុ

ូ ូ ូ

ួ ួ ួ

កុ កូ កួ

តុ តូ តួ

តុ

ក កូ(រ)






មេរៀន ៦

េ ែ ៃ

េ ែ ៃ

កេ កែ កៃ

តេ តែ តៃ

តែ




កកេ(រ)




តា កូ(រ)តែ

មេរៀន៧ : ស្រៈអុំ

# ាំ ះ ុំ

ាំ កាំ តាំ

ះ កះ តះ

ុំ កុំ តុំ

កាំ កះ កុំ

តាំ តះ តុំ

កាំ

កុំ កូ (ៗ)






មេរៀន ៨

ើ ឿ ៀ



កើ កឿ កៀ

តើ តឿ តៀ

ឿ

មេរៀន៩

# ោ ៅ




កោ កៅ

តោ តៅ




កោ(រ)

តោ

តាកៅ

កុំកោ(រ)

ុះ េះ ោះ

ុះ កុះ តុះ

េះ កេះ តេះ

ោះ កោះ តោះ




កោះ

កុះក(រ)

តេះតះ

កុំកេះតុ ។



# មេរៀន ១១ : ស្រះមានចំនួន២៣

ា ិ ី ឹ ឺ

ុ ូ ួ

ើ ឿ ៀ

េ ែ ៃ

ោ ៅ

ុំ ំ ាំ ះ

ុះ េះ ោះ ៗ

មេរៀន ១២

## ព្យញ្ជនៈ ក-ក ត-ត ផ្សំនឹងស្រៈ

ក កា កិ កី កឹ កឺ កុ កូ កួ កើ

កឿ កៀ កេ កែ កៃ កោ កៅ

កុំ កំ កាំ កះ កុះ កេះ កោះ

ត តា តិ តី តឹ តឺ តុ តូ តួ តើ

តឿ តៀ តេ តែ តៃ តោ តៅ

តុំ តំ តាំ តះ តុះ តេះ តោះ

# លំហាត់

ស្ត្រីខ្មែរ ត្បាញ ហូល ផាមួង អន្លូញ សារុង ក្រមា សូត្រ ឬ អំបោះ ។

តើគេប្រើគ្រឿងប្រដាប់អ្វីសំរាប់ត្បាញសំពត់ទាំងនេះ ?



# លំហាត់

ចូរអ្នកសរសេរឈ្មោះឲ្យត្រូវនឹងរូបខាងក្រោមនេះ :

..........



..........



..........



..........



..........



..........



# ជំពូក២ ព្យញ្ជនៈអឃោសៈ

មេរៀន ១៣

## ក ត

កា តិ តី កូ

តុ កាំ តាំ កែ

តួ តើ តែ តោ

តៅ កោះ កេះ




កកូ(រ) កកេ(រ)

តេះតះ តៅ១

តាកៅកូ(រ)តែ។



# ច ជ

ចា ជា ចី ចែ

ជែ ជូ ចៃ ចុះ

ចេះ ជៅ ចៅ

ចោ(រ) ជោះ




ចំកា(រ) ចៅកែ

ច(រ)ចា ចេះជា




តាចេះជែចៅ។

ចៅជូចាំចំកា(រ)។

មេរៀន ១៥

# ប ហ

បា ហា បោះ

បី ហែ ហើ(រ)

បូ ហូ(រ) ហោះ

បៅ បេះ ហោ(រ)




បំបែ(រ) ហូ(រ)ហែ

បប(រ) បះបោ(រ)

បំបៅ កំបោ(រ)

បប(រ)ហៀ(រ) ។



# ដ ផ

ដី ផែ ដេ(រ)

ផា ផៃ ដើ(រ)

ដៃ ផុះ ដាំ




ចុះផែ ដុំដី

ដំបែ ដំបៅ




បូផាបោះដីបីដុំ ។

តាផៃដើ(រ)ចុះផែ។

ចៅផូដាំបប(រ) ។

# ស ណ

សា ណា សី

ណែ សួ(រ) ណៃ

សោ សេះ ណុះ

ដំណាំ ដំណើ(រ)

ចំណោះ ចំណី

ស(រ)សេ(រ) សំដី

សួណាបោះសី ។

តាសៅដាំដំណាំ។

ចៅសំចេះស(រ)សេ(រ)






# ឆ ខ

ឆា ខួ(រ) ឆី ខា

ខាំ ឆេះ ខែ ខៃ

ខោ ឆៅ ខៅ ខះ




ឆាឆៅ ខះក កែខែ

ឆេះខោ ខែសីហា




កុំឆាឆៅតា ។

ចៅឆុំចេះឆា ។

សុខាចេះដេ(រ)ខោ។

# ឡ អ

អូ ឡី អាំ

អា ឡា អេះ

អុំ ឡូ ឡោះ

កៅអី សំឡី

កំឡោះ កីឡា

ឡេះឡោះ សំឡ

កុំឡូឡាអី ។

អំបោះបីហោ ។

តាអាំអេះដៃ ។






# លំហាត់

នៅជិតរូបនីមួយៗ មានឈ្មោះពីរផ្សេងគ្នា។ តើឈ្មោះណាមួយជាឈ្មោះពិតប្រាកដដែលត្រូវនឹងរូបនោះ?

ចូរអ្នកដាក់ក្បៀស(✓) នៅមុខឈ្មោះពិតប្រាកដនោះ ។

| | | | |
|---|---|---|---|
|  | ដៃ<br>ក |  | ថូ<br>ផៃ |
|  | សោ<br>ខោ |  | តោ<br>សេះ |
|  | ចៅ<br>ចៃ |  | កៅអី<br>តុ |

# ជំពូក ៣ ព្យញ្ជនៈឃោសៈ

មេរៀន ២០

## គ

គា គូ គេ គោ

គី គួ គាំ គៀ

គែ គៃ គុំ គោះ




បីគូ គូ(រ) គោបា

កាគី គោះគុ គគី




កុំគោះគុ។

ថៅគាំគូ(រ)គោ ។

មេរៀន ២១

# ភ

ភី ភើ ភែ ភេ

ភំ ភា ភោ ភៅ

សំភី សុភា ភេ

សំភោ ភាសា

កុំភ(រ)គេ ។

តាភុំដាំគគី ។






មេរៀន ២២

# គ ភ

គ គា គិ គី គឹ គឺ គុ គូ គួ គើ

គឿ គៀ គេ គែ គៃ គោ គៅ

គុំ គំ គាំ គះ គុះ គេះ គោះ

ភ ភា ភិ ភី ភឹ ភឺ ភុ ភូ ភួ ភើ

ភឿ ភៀ ភេ ភែ ភៃ ភោ ភៅ

ភុំ ភំ ភាំ ភះ ភុះ ភេះ ភោះ

មេរៀន ២៣

# ព ញ

ពា ញី ពី

ញាំ ញួ ពូ

ពៅ ពោះ ពះ

ញញួ(រ) ពូថៅ

សំពះ ពពែញី

ពុះពា(រ) អំពៅ

សំពៅ ចំពុះ

សុភីពូកែគូ(រ)ញញួ(រ) ។

ពូពៅពិសាញាំពោះគោ ។






មេរៀន ២៤

# រ វ

រាំ វា វី រី

រើ វៃ រៃ រុះ

វះ រោះ វូ វេះ




របាំ រវៃ រុះរើ

ខែរះ វិថី ពិរោះ




សុភីរវៃអំបោះ។

សំដីណាវីពិរោះ។

# ល ឈ

លា ឈឺ លឺ

លើ ឈើ លួ

ឈរ ឈោះ លុះ

លលាដ៍ ឈ្នួរ

រលំ លីលា លំអ

ពូឆាំលិឈើ ។

សុភីឈីពោះ ។

ចៅកែឈរលើឈើ






មេរៀន ២៦

# ម ធ

មី ធូ មើ

មាំ ធួ មេ

ធំ មា មោះ




ធូលី មេអំបៅ

មីសួ មមើ

មមី មមៃ



មេអំបៅហើររេរា។

# ឃ ឃ

ឃួរ ឃា ឃំ

ឃោ ឃូរ ឃុំ

ឃីហោ មេឃុំ

ឃោរឃៅ ឃីកេ







មេឃុំឃូររទី ?

ចៅឃីកុំឃំ ។

តាឃីចេះរាំឃីកេ

# ជ ឈ

ជា ឈា ជី

ឈើ ជូរ ឈុំ

ជួរ ជុំ ឈោះ

ជឿ ជាំ ជិះ




រឈា ជំឈឺ ជីតា

ជំរំ ជំរះ រឈំ




ចៅសុំជិះគោ ។

ជីតាថែជំឈឺចៅ ។

# ទ ន

ទា នា ទី នៅ

ទូ ទើ នំ នេះ

នាំ ទៅ ទុំ ទេះ

ទះដៃ ទំនេរ

ទីនេះ នាទី នារី

រទេះគោ នាឡិកា

ពូជុំបររទេះគោ។

ទីនេះពុំទំនេរទេ។






# ព្យញ្ជនៈមាន៣៣

| | | | | |
|---|---|---|---|---|
| ក | ខ | គ | ឃ | ង |
| ច | ឆ | ជ | ឈ | ញ |
| ដ | ឋ | ឌ | ឍ | ណ |
| ត | ថ | ទ | ធ | ន |
| ប | ផ | ព | ភ | ម |
| យ | រ | ល | វ | ស |
| ហ | ឡ | អ | ។ | |

មេរៀន៣១ :     ប្តូរសម្លេងព្យញ្ជនៈ " បន្តក់ពីរ "

# ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉

ង៉ា ញ៉ែ ប៉ី

យ៉ៃ ញ៉ាំ ម៉ែ

វ៉ៅ ប៉ៅ រ៉ា

ទ្រាយ៉ៃ ដំរី បារី

ចាប៉ី តាប៉ែ ចំប៉ា

តាទៅ ហៅប៉ៅ

តាទៅយំពីរោះ។

កុមារទៅសាលា។






មេរៀន ៣២ : « ត្រីស័ព្ទ »

# អ៊ ប៊ ហ៊ ស៊

អ៊ុ អ៊ូ ប៊ូ ហ៊ូ

ស៊ុ ស៊ូ ហ៊ោ




កៅស៊ូ ទំហ៊ូ តៅហ៊ូ

ភាស៊ុ តស៊ូ សាប៊ូ




ស៊ុណាញុាំនំអ៊ុ ។

ចៅស៊ុំប៉ោះកៅស៊ូ ។

កំឡោះប៊ូទះដៃហ៊ោ។

# លំហាត់

នៅជិតរូបនិមួយៗ មានពាក្យពីរផ្សេងគ្នា ។ តើពាក្យណាមួយ ដែលត្រូវនឹងរូបនោះ ?

ចូរអ្នកដាក់ក្បៀស (✓) នៅមុខពាក្យត្រូវនោះ ។

| | | | |
|---|---|---|---|
|  | លា<br>ពាពែ |  | ទា<br>មេអំបៅ |
|  | សាប៊ូ<br>ចាប៉ី |  | ពូថៅ<br>ញញួរ |
|  | សេះ<br>ដំរី |  | នាឡិកា<br>រទេះ |

# ជំពូក ៤

# ប្រកប

មេរៀន ៣៣ : ប្រកប ន - ណ

កន កន់ កាន កាន់

គន គន់ គាន គាន់

ចាន ចាន់ មាន មាន់

ទាន ទាន់ កិន មិន

កុន មុន ពុន គុណ

ដូន ជូន ពូន កើន

រៀន ពេន បែន មេន



ជីដូន ទាហាន មិនមែន

ចំនួន ចំរើន រៀនអាន



ពូចាន់នាំកូនទៅរៀន ។

មេមាន់មានកូនបួន ។

មេរៀន ៣៤ : ប្រកប យ

# កយ កាយ គយ គាយ




បាយ ចាយ សាយ ងាយ
លាយ កាយ លុយ រុយ
ងុយ ភ្លុយ ជួយ មួយ
ហើយ ឡើយ ដើយ នើយ
រឿយ ដោយ កោយ រោយ




និយាយ រហើយ កកាយ
ជំនួយ រលួយ ទីទុយ

ណារីញ៉ុំាបាយ ។
មេមាន់កកាយដី ។
សុខាខំរៀននិយាយ ។

មេរៀនទី៣៥: ប្រកប ប ព ភ

# កប កុប់ កាប កាប់
# គប គប់ គាប គាប់

ចប ចប់ ចាប ចាប់
ដប ដប់ លប លប់
សាប សាប់ លាបលាភ
ហិប ជួប រូប ទើប
កើប ទៀប បែប អោប




សំណាប ចបកាប់ ជំរាបសួរ
ជួបជុំ រូបភាព បាយដំណើប

ពូគាំលីចបកាប់ទៅចំការ ។
សុភាពញាំុបាយដំណើប ។
សុភាពចេះជំរាបសួរម៉ែ ។



មេរៀន ៣៦ : ប្រកប វ

# កាវ គាវ

អាវ បាវ ដាវ

លាវ ផាវ ទាវ

ខៀវ កែវ ឡេវ

រដូវ គុយទាវ

សៀវភៅ សាវម៉ាវ

រងាវ រដូវរងា







មាន់រងាវ ។

សុភីដេរអាវខៀវ ។

ចៅកែវមានសៀវភៅមួយ។

សារិកាកែវចេះនិយាយ ។

មេរៀន៣៧ : ប្រកប ម

# កម កាម គម គាម

តាម ចាម នាម ទាម
នឹម បូម ហើម បៀម
ទៀម ចោម រោម គោម




ចំពាម ទំនៀម ចោមរោម

បូករួម សំបើម ចំណោម

ដើមទទឹម គោមួយនឹម




ពូគឹមទឹមរទេះគោ ។

ពូគាំដើរតាមគោ ។

ចៅកែវពួនកៀនដើមទទឹម ។

# កាច កាច់

សាច សាច់ ដាច ដាច់
បាច បាច់ រាជ តិច
ទិច ហុច តូច ដូច
បោច ពូជ រួច សើច
វៀច លេច ខូច ទោច




មិនបាច់ បំណាច់
សំពោច សំណើច
កំទេច សាច់គោ




ចៅសំសើចតិចៗ ។
សុភីហុចសៀវភៅ ។
អាវនេះដាច់ឡេវមួយ ។

## មេរៀន ៣៩ : ប្រកប ង

# កង កង់ កាង កាំង
# គង គង់ គាង គាំង

ចង ចង់ ទង ទង់

តាង តាំង ពាង ពាំង

ចុង ខឹង មឹង រឹង

ដូង ឡើង ជើង លៀង

ឆៀង លេង កោង សាំង




កំឡាំង រនាំង ននោង

ធាងដូង ដំឡូង ដើមដូង




ពូគាំឡើងដើមដូង ។

យើងដើររលេងតាមភូមិ ។

សុខាជិះកង់ទៅចំការដូង ។

## មេរៀន ៤០ : ប្រកប ញ

# កញ កញ់ កាញ កាញ់




សាញ បាញ់ ទាញ ទិញ

វិញ ធុញ សុញ រុញ

លុញ ជួញ រួញ ចាញ់

ឃើញ ពេញ ចេញ ដេញ

សំឡាញ់ សំណាញ់ ទំនិញ

ជំនួញ បំពេញ ចំណេញ




ដំរីទាញឈើហ៊ុប ។

បងសុភីទិញមាន់ទៅជួញ ។

ពូគាំទៅបង់សំណាញ់នៅបឹងធំ ។

មេរៀន ៤១ : ប្រកប ល

# កល កល់ កាល កាល់
# គល គល់ គាល គាល់

ផាល វាល ជាល វិល

ពុល ជុល ទូល ដួល

ទួល មើល ដៀល ពេល

ដែល ខែល ចោល បោល

គោល យោល ប៉ោល រោល




អំបិល ដីវាល កំស្ទួល

ដីទួល ពេលវេលា ។

សុផលទៅទិញអំបិល ។

គេដាំដំឡូងលើដីទួល ។



មេរៀន៤២ : ប្រកប ស

# កស កស់ កាស កាស់

# គស គស់ គាស គាស់

ចាស់ ដាស់ ណាស់

វ៉ាស់ រស់ ពាស

ពស់ ជួស កោស

លួស រើស ញើស

ចៀស មូស រនាស់







តាចាស់ មូសខាំ ឈូសឈើ

បែកញើស កំពីស កោសដូង

មីងណាតកោសដូង។

ជាងឈើជួសជុលតុសិស្ស។

## មេរៀន៤៣ : ប្រកប ក.ខ.គ.ឃ

# កក កក់ កាក កាក់
# គក គក់ គាក គាក់

ដាក់ ចាក់ ពាក់ ភាគ

ចឹក រុក ទុក មុខ

សុខ សូក ទូក ពូក

មួក បើក លើក ចេក

សេក ចែក បែក មេឃ

បោក ដោក លោក រោគ







ដំដែក បំបែក ទឹកកក

ពាក់មួក សំបកចេក អំពិលទឹក

កុំដេកនៅទីនេះ ។

សេកទំលើមែកអំពិលទឹក ។

មេរៀន ៤៤ ប្រកប ត ទ

# កិត កិត់ កាត កាត់

ខាត ខាត់ បាត បាត់

គាត់ ធាត់ វាត់ ឃាត់

សិត គិត បិទ ឃិត

ដុត មុត ជូត អួត

កេត ងៀត ដោត ពោត




កាំបិត សំពត់ កាសែត




ពូគាំទៅចំការពោត ។

តាខាត់អានកាសែត ។

កុំលេងកាំបិតវាមុតដៃ ។

សុភីកើតនៅខេត្តកំពត ។

# លំហាត់




ចូរអ្នកសរសេរឈ្មោះ ដំណាំ និងសត្វស្រុកដែលអ្នកឃើញ ក្នុងរូបខាងលើនេះ ÷

១ . . . . . . .　　　　៤ . . . . . . . .

២ . . . . . . .　　　　៥ . . . . . . . .

៣ . . . . . . .　　　　៦ . . . . . . . .

# លំហាត់

ចូរអ្នកសរសេរឈ្មោះឲ្យត្រូវនឹងរូបនិមួយៗខាងក្រោមនេះ ៖

-------



-------



-------



-------



-------



-------



# ជំពូក ៥

## ផ្ញើជើង

### មេរៀន ៤៥ : ជើងព្យញ្ជនៈ

| | | | | |
|---|---|---|---|---|
| ក ្ក | ខ ្ខ | គ ្គ | ឃ ្ឃ | ង ្ង |
| ច ្ច | ឆ ្ឆ | ជ ្ជ | ឈ ្ឈ | ញ ្ញ |
| ដ ្ដ | ឋ ្ឋ | ឌ ្ឌ | ឍ ្ឍ | ណ ្ណ |
| ត ្ត | ថ ្ថ | ទ ្ទ | ធ ្ធ | ន ្ន |
| ប ្ប | ផ ្ផ | ព ្ព | ភ ្ភ | ម ្ម |
| យ ្យ | រ ្រ | ល ្ល | វ ្វ | ស ្ស |
| ហ ្ហ | ឡ | អ ្អ | ។ | |

មេរៀន ៤៦

# ក្រ ច្រ ត្រ ប្រ ស្រ
# គ្រ ជ្រ ទ្រ ព្រ ម្រ

ក្របី ក្រពើ ក្រហម គ្រួស
ច្រវា ត្រី ស្រី ស្រះ
ស្រែ ត្រប់ ស្រូវ ប្រុស
គ្រែ គ្រូ គ្រប់ ជ្រៃ
ជ្រោះ ជ្រៅ ទ្រាំ ទ្រុង
ព្រៃ ព្រះ ម្រេច ម្រះ




ស្រុកស្រែ ព្រោះស្រូវ កំព្រា
ជ្រូកព្រៃ ទ្រុងជ្រូក ព្រលឹម




ត្រូវលបលាងមុខរាល់ព្រឹក ។
ជ្រូកព្រៃដេកក្រោមដើមជ្រៃ ។
ព្រឹកព្រលឹមស្រីៗទៅច្រូតស្រូវ ។

# ក្ង ក្ត ក្ន ក្ម ក្ល ក្ប ក្យ ក្អ

# ខ្ច ខ្ញ ខ្ន ខ្ម ខ្ល ខ្វ ខ្យ ខ្ស

ក្ងោក ក្តាម ក្នុង ក្មេង

ក្លាយ ក្បាល ក្អក ក្អែក

ខ្ចី ខ្ញុំ ខ្នង ខ្មែរ

ខ្លា ខ្លែង ខ្វះ ខ្វែក

ខ្យង ខ្យល់ ខ្សែ ខ្សោយ




ទឹកខ្មះ ខ្មៅដៃ ខ្សត់ខ្សោយ

ក្លាហាន ខ្លាធំ ក្បោះក្បាយ




ស្រីដងទឹកដាក់ក្អម ។

ក្មេងៗចាប់ក្តាមខ្យងនៅក្នុងស្រែ។

សុខានិយាយបានក្បោះក្បាយណាស់។

មេរៀន ៤៨ :

# គ្ន គ្ម ឃ្ន ឃ្ម ឃ្ល ឃ្វ ហ្វ




គ្នា គ្នី គ្មាន ឃ្មុំ

ឃ្នាប ឃ្នាង ឃ្លាត ឃ្លោក

ឃ្លាន ឃ្វាល ឃ្វាង ហ្វូង

ឃ្លៀងឃ្លាត កាហ្វេ ហ្វូងគោ

ទ្រើងឃ្លោក គ្នីគ្នា អត់ឃ្លាន

មីងខ្ញុំជ្រួយដីដាំឃ្លោក ។

ក្មេងៗនាំគ្នាទៅឃ្វាលគោ ។

ខ្លាឃ្មុំឡើងដើមឈើ យក

ឃ្មុំជាអាហារ ។

មេរៀន ៤៩

# ច្ប ឆ្ក ឆ្ង ឆ្ន
# ឆ្ម ឆ្ល ឆ្វ ឆ្អ

ច្បារ ច្បាប់ ឆ្កា
ឆ្កែ ឆ្ងល់ ឆ្ងាញ់
ឆ្នាំង ឆ្វេង ឆ្នៃ
ឆ្វែល ឆ្មា ឆ្លង
ឆ្អែត ឆ្អិន ឆ្អឹង




ត្រីឆ្ដោរ ក្រូចឆ្មារ ឆ្លេឆ្លា
ឆ្អឹងជំនីរ ច្បារដំណាំ




ឆ្កែដេញខាំឆ្មា ។
ដៃឆ្វេងសំរាប់កាន់ក្ដារ ។
សំឡកកូរមានរសជាតិឆ្ងាញ់ ។
បងស្រីខ្ញុំដាំបាយនឹងឆ្នាំង ។

មេរៀន ៥០

# ជ្វ ឈ្ង ឈ្ន ឈ្ម ឈ្ល ឈ្វ

ជ្វា ឈ្ងោក ឈ្ងុយ

ឈ្ងប់ ឈ្នាន់ ឈ្នាង

ឈ្នះ ឈ្មោល ឈ្មោះ

ឈ្លោះ ឈ្លើង ឈ្វេង

ឈ្ងុយឈ្ងប់ ឈ្នាងត្រាំ

មាន់ឈ្មោល ឈ្លានពាន

ឈ្លោះគ្នា ឈ្វេងយល់

យើងមិនត្រូវឈ្លោះគ្នាទេ ។

ជីតាខ្ញុំមានជ្រូកឈ្មោលប្រាំ ។

ផ្កាចំប៉ាមានក្លិនឈ្ងុយឈ្ងប់ ។

ពូគាំលើកឈ្នាងបានត្រីច្រើន ។






# ត្អ ត្ន ត្ម ត្ល ត្យ
# ថ្ក ថ្ង ថ្ន ថ្ម ថ្ល ថ្វ



ត្អូញ ត្នោត ត្មាត ត្មោង
ត្លុក ត្បាល់ ត្បាញ ថ្កូវ
ថ្ងាស ថ្ងៃ ថ្នល់ ថ្នាក់
ថ្នម ថ្នាំ ថ្ម ថ្មី
ថ្លា ថ្លង់ ថ្វាយ ថ្វី

ត្អូញត្អែរ ដើមត្នោត ថ្នាំគ្រុន
ត្បាល់កិន ថ្នាក់ថ្នម ថ្វីដៃ

ម៉ែខ្ញុំត្បាញសំពត់ហូល ។
មាខ្ញុំពូកែឡើងដើមត្នោត ។
ជីដូនទិញក្រូចត្លុងចែកចៅ ។

មេរៀន ៥២

# ទ្វ ធ្ង ធ្ន ធ្ម ធ្ល ធ្វ ធ្យ

ទ្វារ ទ្វេ ទ្វីប ធ្ងន់
ធ្នូ ធ្នាក់ ធ្មេញ ធ្មង់
ធ្លា ធ្លាក់ ធ្លាយ ធ្វើ
ធ្វេស ធ្យូង ធ្នឹម ធ្មៃ




ធ្ងន់ធ្ងរ ធ្មេញត្រី ខែធ្នូ
ទីធ្លា ដើមធ្មៃ ធ្វើការ




មាខ្ញុំកាប់ព្រៃធ្វើចំការ ។
តាខ្ញុំដុតឈើធ្វើធ្យូង ។
សាលារៀនខ្ញុំមានទ្វារធំៗច្រើន។
ពេលចេញលេង សិស្សនាំគ្នា
រត់លេងពេញទីធ្លាសាលា ។

មេរៀន ៥៣

# ប្ដ ប្ល ប្អ

# ផ្ក ផ្ដ ផ្ស ផ្ច ផ្ញ ផ្ន ផ្ល ផ្ស ផ្អ




ប្ដី ប្លែក ប្អូន ផ្កា

ផ្ដៅ ផ្សារ ផ្ចង់ ផ្ញើ

ផ្នត់ ផ្លូវ ផ្សិត ផ្អែម

បងប្អូន ប្ដីប្រពន្ធ ផ្ចិតផ្ចង់

ផ្លូវថ្នល់ ផ្លែឈើ ផ្សៀងផ្អង




ម៉ែខ្ញុំទៅផ្សារទិញសំពត់ផ្ញើ

ប្អូនស្រីខ្ញុំ ។

លោកគ្រូបានផ្ដែផ្ដាំថា៖

កុំលេងតាមផ្លូវថ្នល់ ។

មេរៀន ៥៤

# ព្ន ព្យ ភ្ង ភ្ជ ភ្ញ ភ្ន ភ្ល
# ម្ង ម្ជ ម្ញ ម្ន ម្ព ម្ភ ម្យ ម្ល

ព្នៅ ព្យុះ ភ្ងា
ភ្លេង ភ្ញាក់ ភ្នំ
ម្ជុល ម្នាស់ ភ្ជុំ
ម្ទេស ម្លប់ ម្ភៃ




ខ្យល់ព្យុះ ផ្លែព្នៅ ភ្ជួរស្រែ
ផ្កាម្លិះ ភ្នំពេញ ភ្លុកដំរី
លេងភ្លេង ម្លប់ឈើ ម្នីម្នា




ជីតាខ្ញុំដាំចេក ដូង ម្នាស់ ម្លូ
និងម្ទេសនៅចំការក្រោយផ្ទះ។
ពេលភ្លឺស្រាងៗបងប្រុសខ្ញុំ
ចេញទៅភ្ជួរស្រែ ។

# ល្ង ល្ព ល្ម ល្វ ស្ក ស្ង ស្ម
# ស្ត ស្ន ស្ប ស្ម ស្ល ស្វ ស្អ




ល្ងាច ល្ពៅ ល្មុត ល្វីង
ស្ងោរ ស្ករ ស្កូវ ល្វើយ
ស្ងើប ស្តោះ ស្វា ស្បែក
ស្អាត ស្មៅ ស្លា ស្នប់

ស្បែកជើង ថ្ងៃល្ងាច ផ្លែស្វាយ
ស្មោះត្រង់ ដៃស្តាំ ត្រីស្ងោរ
ស្វិតស្វាញ ស្អុះស្អាប់ ស្លឹកឈើ




ជីដូនខ្ញុំចូលចិត្តពិសា ស្លាខ្ចី ។
ចំការជីតាខ្ញុំមានដើមឈើស៊ី
ផ្លែជាច្រើនដូចជា ដូង ស្លា
ល្មុត ក្រូចនិងចេកជាដើម ។

# ខ្ជ ខ្ទ ខ្ព ឆ្គ ឆ្ព ថ្ព
# ថ្គ ផ្គ ផ្ទ ស្គ ស្ទ ស្ព

ខ្ជឹង ខ្ទម ខ្ទះ ខ្ពស់

ឆ្គង ឆ្ពោះ ស្គម ស្គរ

ថ្ពាល់ ថ្គាម ផ្គរ ផ្ទះ

ស្ទឹង ស្ពាន ស្ពៃ ស្ពាន់




ត្រីខ្ជឹង ស្វាយខ្ទិះ ខ្ទះត្នោត
ផ្គរលាន់ ស្ពៃក្តោប ត្រីឆ្ពិន




ពូគាំយកទឹកត្នោតទៅចាក់ក្នុងខ្ទះ។
ម្តាយសុធីដាំស្ពៃក្តោបនៅក្បែរផ្ទះ។
ក្មេងៗនាំគ្នាទះស្គរយីកេ ។
កុមារាកុមារីដើរឆ្ពោះទៅសាលា។

មេរៀន ៩៧

# ម្ក ម្ខ ម្ច ម្ដ ម្ស ម្ហ ម្អ
# ល្ខ ល្ប ល្ហ ល្អ




ម្កាក់ ម្ខាង ម្ចាស់ ម្ដាយ

ម្ដង ម្សៅ ម្ហូប ម្អម

ល្ខោន ល្ហុង ល្បែង ល្អី

ត្រើយម្ខាង ម្ចាស់ផ្ទះ ម្សៅមី

ល្បីល្បាញ ដូចម្ដេច ផ្លែម្កាក់




ល្ខោនសំដែងរឿងល្អៗ ។

ម្ដាយខ្ញុំបេះល្ហុងមកធ្វើជ្រក់ ។

ម្ចាស់ផ្ទះធ្វើម្ហូបទទួលភ្ញៀវ ។

មុខផ្ទះសុភីមានដើមម្កាក់ខ្ពស់។

# លំហាត់




នៅក្នុងសួនសត្វគេឃើញ៖ ក្រពើ ជ្រូកព្រៃ ក្ងាន ក្ងោក ស្វា ប្រើស ខ្លា ខ្លាឃ្មុំ ។ ចូរអ្នករើសពាក្យខាងលើនេះមកដាក់តម្រូវតាមលេខឲ្យត្រូវនឹងរូបខាងលើ ។

១.........
២.........
៣.........
៤.........
៥.........
៦.........
៧.........
៨.........

# ជំពូក ៦ ព្យាង្គតម្រួត

## មេរៀន ៥៨ : ព្យាង្គតម្រួតមានអក្សរ ក.ង នៅកណ្ដាល




អង្ករ កង្កែប ចង្កេះ
គីង្គក់ ចង្កូត បង្គី
បង្រួញ មង្ឃុត អង្គរ
បង្ហាញ បង្ហិច បង្វំ
បង្ហាត់ បង្អែម ចង្អុល




ថ្វាយបង្គំ អង្គរវត្ត
ចង្កូតឡាន ផ្លែមង្ឃុត

សុខាយកបង្គីទៅកើបអង្កាម។
បង្កងស្ងោរមានរស់ជាតិឆ្ងាញ់។
ខ្ញុំអង្គុយរៀបផ្លែមង្ឃុតដាក់ក្នុងល្អី

# មេរៀន ៥៩ :  ព្យាង្គតម្រួតក្រោមអក្សរ “ ញ ”

កញ្ច័ ចិញ្ចឹម កញ្ចុំ

ចិញ្ចើម ចិញ្ចៀន បញ្ចុះ

កញ្ឆ័ត បញ្ឆេះ កញ្ជើ

ជញ្ជាំង ជញ្ជីង បញ្ជី

បញ្ឈៀង បញ្ឈរ ជញ្ជូន




ត្រីកញ្ចុះ កញ្ចាញ់ចេក

ចិញ្ចើមថ្នល់ បញ្ចុះបញ្ចូល




ម្ដាយសុធីពាក់ចិញ្ចៀននៅម្រាមដៃ ។

កសិករនាំគ្នាជញ្ជូនស្រូវដាក់ជង្រុក ។

លោកគ្រូបើកបញ្ជីហៅឈ្មោះសិស្ស ។

មេរៀន ៦០

# ព្យាង្គតម្រួតមានអក្សរ ន នៅកណ្ដាល

សន្ដាន បន្ទុយ កន្ទាំង
បន្ទប់ បន្ទះ បន្ថែម
ពន្លាក កន្សែង មន្ទីរ
ពន្យល់ គន្លង អន្ទាក់
ទន្សាយ សង្កាត់ កន្ត្រៃ

បន្ទះក្ដារ បន្ទប់រៀន
ត្រីកន្ត្រប់ មន្ទីរពេទ្យ







លោកគ្រូផ្ដាំថា៖ "ចេះមកពីរៀន"
ខ្ញុំថែទាំសំអាតបន្ទប់រៀន ។
សុខាឈឺធ្មេញ វាទៅមន្ទីរពេទ្យ។
កាលណាដល់ផ្លូវពិបាក ពូគាំ
បររទេះគោបន្ថយល្បឿន ។

មេរៀន ៦១

ព្យញ្ជនៈតម្រួតមាន : អក្សរ ដ.ណ.ប.ម នៅកណ្ដាល




កណ្ដាល កណ្ដុរ ស្ដេង
បណ្ដែត បណ្ដោយ បណ្ដុះ
សណ្ដែក កប្បាស បុប្ផា
អប្សរា កម្ពុជា កម្មករ

កណ្ដាប់ស្រូវ សណ្ដែកដី
ប្រទេសកម្ពុជា ផ្លែកប្បាស




គេដាំសណ្ដែកនៅមាត់ទន្លេ។
ប្រទេសកម្ពុជាសម្បូរត្រីណាស់។
កណ្ដុរជាសត្វចង្រៃ វាបំផ្លាញ
ដំណាំ ។

មេរៀន ៦២ :   ស្រះពេញតួ

# ឥ ឦ ឧ ឩ ឫ ឬ
# ឭ ឮ ឯ ឰ ឱ ឳ

ឥឡូវ ឦសាន ឪពុក ខ្លែងឯក ឯកសារ ឱកាស ឫស្សី ក្រឡឹឈូក ឧត្ដរ




ឥឡូវនេះយើងនាំគ្នាទៅកាប់ ឧសឯព្រៃ ។ គេដាំឪឡឹកនៅ មាត់ទន្លេសាប ។ ឪពុកខ្ញុំទើប ត្រឡប់មកពីឧត្ដរមានជ័យ ។ ខ្ញុំឮសម្លេងខ្លែងឯកនៅឰដ៏អា កាស ។ បងស្រីខ្ញុំទៅដកក្រឡឹ ឈូកឯបឹងធំ ។ នៅប្រទេសខ្មែរ គេប្រើឫស្សីសំរាប់ធ្វើផ្ទះនិងប្រ ដាប់ប្រើប្រាស់ផ្សេងៗ ។



# លំហាត់

ចូរអ្នកសរសេរឈ្មោះឲ្យត្រូវនឹងរូបនីមួយៗ ខាងក្រោមនេះ ៖



----------



----------



----------



----------



----------



----------

# ជំពូក ៧

- អត្ថបទ
- ចំរៀង
- រឿងកំសាន្ត
- រឿងព្រេងខ្មែរ

មេរៀន ៦៣ : អត្ថបទ

# ចេះមកពីរៀន

រាល់ថ្ងៃខ្ញុំទៅសាលារៀន ។ ខ្ញុំខំរៀនអាននិងហាត់សរសេរអក្សរ ។ ខ្ញុំធ្វើលេខបូក លេខសង លេខគុណ លេខចែកបានល្អ ។ អ្នកគ្រូញញឹមហើយសរសើរខ្ញុំថា ៖ ឯងរៀនឆាប់ចេះសមដូចសុភាសិតខ្មែរចែងថា "ចេះមកពីរៀន" ។

ខ្ញុំសប្បាយចិត្តណាស់ ។ ខ្ញុំខំរៀនអោយកាន់តែចេះច្រើនថែមទៀត ។



មេរៀន ៦៤ : អត្ថបទ

# សិស្សល្អ

រាល់ព្រឹក សុខារៀបចំខ្លួនចេញទៅសាលា។សុខាមកដល់សាលារៀនទាន់ពេលជាដរាប ហើយមិនដែលឈប់ ដោយឥតបានសុំច្បាប់លោកគ្រូឡើយ ។

សុខាចូលចិត្តសំអាតសំលៀកបំពាក់។ សុខាជួយថែទាំប្រដាប់ប្រដាសំរាប់រៀនសូត្រនិងថែទាំបន្ទប់រៀនអោយបានគង់វង្សល្អ។ សុខាយកចិត្តទុកដាក់ស្តាប់លោកគ្រូពន្យល់គ្រប់ពេលវេលា។

សុខាមិនធ្វើអោយរំខានឬឈ្លោះប្រកែកជាមួយនឹងសិស្សដទៃឡើយ។ សុខាព្យាយាមធ្វើតាមដំបូន្មានរបស់លោកគ្រូ។ លោកគ្រូបានសរសើរថា : សុខាជាសិស្សល្អ ។



មេរៀន ៦៥ : អត្ថបទ

# សិស្សស្អាត

រាល់ថ្ងៃ សុខាងូតទឹក សំអាតខ្លួន និងដុសលាងដៃជើង ។ សុខាកាត់ក្រចក និងសំអាតសំលៀកបំពាក់ជាដរាប ។

នៅក្នុងថ្នាក់រៀន សុខាមិនខាកស្តោះ ឬចោលសំរាមក្រោមតុឡើយ ។ សុខាថែរក្សាសៀវភៅ និងប្រដាប់ប្រដាសំរាប់រៀនបានល្អជារៀងរាល់ថ្ងៃ ។

នៅតាមទីធ្លា ឬកន្លែងសាធារណៈ សុខាមិនចោលសំរាមផ្តេសផ្តាស ឬបន្ទោរបង់ឥតសណ្តាប់ធ្នាប់ដែលនាំអោយធុំក្លិនអាក្រក់ និង បណ្តាលអោយកើតមេរោគឆ្លងផ្សេងៗ ។

លោកគ្រូសរសើរសុខាថា :"សុខាជាក្មេងចេះសំអាត " ។



មេរៀន ៦៦ : អត្ថបទ

# ក្មេងគួរសម

សុភីចេះគួរសម គោរពនិងស្តាប់បង្គាប់ឪពុកម្តាយ។ នាងចេះស្រឡាញ់បងប្អូននិងរាប់អានញាតិជិតខាងណាស់ ។

នៅសាលានាងតែងគោរពហើយស្តាប់បង្គាប់លោកគ្រូជានិច្ច។ សុភីយកចិត្តទុកដាក់ខំរៀនសូត្រ ហើយចេះរាប់អានមិត្តរួមថ្នាក់ជាមួយនាង ។

នៅទីប្រជុំជន ឬក្នុងពិធីបុណ្យផ្សេងៗ គេតែងឃើញនាងមានទឹកមុខញញឹម សំដីទន់ភ្លន់ទៅកាន់ចាស់ទុំ ។



មេរៀន៦៧ : អត្ថបទ

# ល្បែងកំសាន្ត

នៅពេលចេញលេង សិស្សទាំងឡាយនាំគ្នាលេងជាក្រុមៗនៅក្នុងទីធ្លាសាលា។ សិស្សខ្លះលោតអន្ទាក់ លោតខ្សែ លោតមឹក។ ក្រុមខ្លះទៀតលេងលាក់កន្សែង ចាប់កូនខ្លែង និងលេងស្វាដណ្ដើមទី។ រីឯកុមារខ្លះទៀតនាំគ្នាអង្គុយលេងបាយខុំ លេងត្រែះសើចក្អាកក្អាយគ្រប់ៗគ្នា។ ចំណែកកុមារតូចៗ លេងបោះកូនឃ្លីយ៉ាងសប្បាយរីករាយ។

នៅក្នុងភូមិ និងតាមវត្តអារាមនាឱកាសចូលឆ្នាំថ្មី ឬនៅពេលមានបុណ្យទានម្ដងៗ ខ្មែរយើងនាំគ្នាលេងល្បែងកំសាន្តដូចជា៖ ចោលឈូង បោះអង្គុញ ទាញព្រ័ត្រជាដើម ។



មេរៀន ៦៨ : អត្ថបទ

# កុមារភៀសខ្លួនខ្មែរ

កាលសុខាពុំទាន់ចូលរៀននៅឡើយ សុខាតែងតែរត់លេងជាមួយកុមារឯទៀតៗ ដែលរស់នៅក្នុងជំរំ ។

ចាប់តាំងពីសុខាបានចូលមកទទួលការអប់រំ នៅក្នុងសាលាបឋមសិក្សាក្នុងជំរំពេលណា សុខាក៏បានក្លាយខ្លួនជាសិស្សគំរូដល់ក្មេងទាំងឡាយ។ សុខាមករៀនរាល់ថ្ងៃ ហើយទៀងពេល ។ សុខាសំអាតខ្លួនប្រាណហើយយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ស្ដាប់បង្គាប់លោកគ្រូ។ សុខាសំអាតបន្ទប់រៀនមិនចោលសំរាមផ្ដេសផ្ដាស់ ឬបន្ទោរបង់ឥតសណ្ដាប់ធ្នាប់ឡើយ។

នៅផ្ទះ សុខាជួយធ្វើការឪពុកម្ដាយ ។ ញាតិជិតខាងស្រឡាញ់រាប់អានសុខាណាស់ ព្រោះសុខាជាក្មេងចេះគួរសម ហើយព្យាយាមរៀនសូត្រ ។ ឪពុកម្ដាយសុខាសប្បាយចិត្តណាស់ដោយឃើញកូនមានកិរិយាប្រពៃដូច្នេះ ។

កុមារទាំងឡាយ ចូរអ្នកយកគម្រប់តាមសុខា អ្នកនឹងបានទៅជាពលរដ្ឋថ្លៃថ្នូរសំរាប់ប្រទេសជាតិទៅថ្ងៃក្រោយ ។



មេរៀន ៦៩ : ចំរៀង



# សារិកាកែវ




១. សារិកាកែវអើយ ស៊ីទឹកងៗ ហៃសារិយ៉ាំង (ស្ទួន)
ស៊ីផ្លែដំបង ប្រចឹកគ្នាលេង អើយកែវៗអើយ ។

២. ស្លាបវាចាក់ក្បាច់ មាត់វាផ្ទើភ្លេង ហៃសារិយ៉ាំង (ស្ទួន)
ប្រចឹកគ្នាលេង លើមែកព្រឹក្សា អើយកែវៗអើយ ។

មេរៀន ៧៦ ៖ អត្ថបទ

# ដំណាំ និង ព្រៃឈើ

នៅប្រទេសខ្មែរ មានដំណាំច្រើនយ៉ាង៖ ស្ពៃ សាឡាដ ជីរ ត្រឡាច ត្រសក់ ឃ្លោក ននោង ល្ពៅ សំរាប់ជាបន្លែ ។

ខ្មែរយើងចូលចិត្តធ្វើចំការដូចជា៖ ចំការដំឡូង ពោត អំពៅ សណ្តែក ក្រូច ម្នាស់ ចេក ដូង កប្បាស កៅស៊ូ ។ ដើមឈើខ្លះផ្តល់ជាផ្លែសំរាប់បរិភោគ ។ គេដាំកប្បាស សំរាប់ធ្វើអំបោះត្បាញសំពត់ ។ កៅស៊ូផ្តល់ជ័រសំរាប់ស្លធ្វើកង់ឡាន ស្បែកជើង ។ គេដាំកៅស៊ូនៅកំពង់ចាម និង ក្រចេះ ។

នៅប្រទេសខ្មែរ សម្បូណ៌ព្រៃឈើដែលអាច ផ្តល់ឈើល្អៗ ដូចជា បេង នាងនួន គគី ស្រឡៅ ។ ឈើខ្លះសំរាប់សង់ផ្ទះ ខ្លះទៀតសំរាប់ធ្វើតុ ទូ ។



មេរៀន ៧១ : អត្ថបទ

# សត្វនៅប្រទេសខ្មែរ



ខ្មែរចូលចិត្តចិញ្ចឹមសត្វណាស់ គេចិញ្ចឹមជ្រូកមាន់ទានៅតាមផ្ទះដើម្បីធ្វើជាអាហារ ។

ចំណែកកសិករយើងចិញ្ចឹមគោក្របី សំរាប់អូសរទេះ និងទាញនង្គ័ល។ គេប្រើសេះធ្វើជាជំនិះបានលឿនទាន់ចិត្ត។ គេចិញ្ចឹមឆ្កែសំរាប់អោយចាំផ្ទះ និងចិញ្ចឹមឆ្មាសំរាប់អោយចាប់កណ្ដុរ។



នៅក្នុងបឹង ត្រពាំង ស្ទឹង ទន្លេ សមុទ្រ មានត្រី អណ្ដើក កន្ធាយ ក្ដាម ខ្យង បង្កង ក្រពើជាច្រើន ។

នៅក្នុងព្រៃមានសត្វច្រើនណាស់ដែរ ។ សត្វទាំងនោះរស់នៅជាហ្វូងៗ ដូចជាទន្សោង ឈ្លូស រមាំង ក្ដាន់ ដំរី ខ្លា ជាដើម ។

មេរៀន ៧២ : អត្ថបទ

# ស្រូវនិងត្រីនៅប្រទេសខ្មែរ



ស្រូវជាដំណាំសំខាន់ជាងគេនៅប្រទេសខ្មែរ។ កសិករធ្វើស្រែរៀងរាល់ឆ្នាំ ។

លុះដល់រដូវច្រូតកាត់ម្ដងៗគេបានផលស្រូវយ៉ាងច្រើន។ គេយកស្រូវទៅកិនធ្វើជាអង្ករ។ ខ្មែរយើងយកអង្ករនេះមកចំអិនជាបាយបរិភោគរៀងរាល់ថ្ងៃ ។



ត្រីក៏ជាអាហារសំខាន់របស់ខ្មែរយើងដែរ ។ គេនេសាទ ត្រីនៅតាមបឹងទន្លេសាប និង ដងទន្លេមេគង្គ ។ រីឯសមុទ្រខ្មែរយើងក៏សំបូរត្រីដែរ ត្រីនោះគេហៅថាត្រីទឹកប្រៃ ។

មេរៀន ៧៣ : ចំរៀង




បង អុំ ទូក ទៅ ឱ ណានាងណា ឮ សូរគ្រូក
គ្រូក បង អុំ ទូក ទៅ ឱ ណានាង
ណា ឮ សូរគ្រូក គ្រូក ទៅ បេះទៅបេះ ផ្កា
ឈូក ឱ ណានាងណា ដុះក្នុងបឹង កក់ ទៅ
បេះ ទៅ បេះផ្កា ឈូក ឱ ណានាងណា ដុះក្នុងបឹង
កក់ ឱ ផ្កាឈូក

ទំនុកច្រៀង

# អុំទូក

១. បងអុំទូកទៅ ឱណានាងណា ញូស្ទូរគ្រូកៗ (ស្ងួន)
ទៅបេះៗផ្កាឈូក ឱណានាងណា ដុះក្នុងបឹងកក់ (ស្ងួន)។

២. ឱផ្កាឈូកអើយ ឱណានាងណា ដុះចេញពីភក់ (ស្ងួន)
គួរផុំៗអាក្រក់ ឱណានាងណា ម្ដេចឡើយឈ្ងុយឈ្ងប់ (ស្ងួន)។

៣. ទាំងមើមក្រអៅ ឱណានាងណា ទាំងម្សៅឈ្ងុយសព្វ (ស្ងួន)
ដុះក្នុងៗដីល្បប់ ឱណានាងណា ត្រឡប់ជាល្អ (ស្ងួន)។



មេរៀន ៧៤ : រឿងកំសាន្ត

## ដំរី និង ស្រមោច



ថ្ងៃមួយ ដំរីបានឃើញស្រមោច កំពុងលង់ទឹក។ ដំរីកាច់មែកឈើមួយ បោះអោយស្រមោចវារឡើងមកលើគោកវិញ ។ ដំរីបានជួយស្រមោចអោយផុតពីសេចក្ដីស្លាប់ ។



ថ្ងៃក្រោយមកទៀត ដំរីទៅស៊ីស្មៅក្បែរត្រពាំងនោះ ។ ព្រានព្រៃឃើញដំរីក៏លបបាញ់ ។ ដំរីមិនដឹងខ្លួនសោះ ។



ស្រមោចរស់នៅទីនោះ បានឃើញដូច្នោះ ក៏វារឡើងទៅខាំជើងព្រានព្រៃ ។ ព្រានភ្ញាក់ព្រើតរបូតព្រួញពីដៃ ដំរីក៏ផ្អើលរត់បោលទៅ។ ស្រមោចបានជួយដំរីវិញ ។

"យើងត្រូវចេះជួយគ្នាទៅវិញទៅមក"

# សិល្បៈខ្មែរ



ខ្មែរមានសិល្បៈប្រចាំជាតិរបស់ខ្លួន សំណង់ ចម្លាក់ ភ្លេង ចំរៀង របាំល្ខោន ណាំងស្បែកនិងកំណាព្យ មានលក្ខណៈជារបស់ខ្មែរសុទ្ធសាធ។

យូរយារណាស់មកហើយ ខ្មែរបានសាងប្រាសាទជាច្រើនទុកជាកេរ្តិ៍ដំណែលដល់កូនខ្មែរគ្រប់រូប ។

ចម្លាក់នៅតាមប្រាសាទនានាសុទ្ធសឹងតែល្អប្រណីត ។ របាំខ្មែរមានចលនាទន់ភ្លន់ប្រៀបដូចទឹករលក។ គេតែងលេងល្ខោន ណាំងស្បែក ត្រុត យីកេ ឆៃយ៉ាំ នៅពេលបុណ្យទានម្តងៗ។ ខ្មែរម្នាក់ៗចេះច្រៀងចំរៀងបុរាណ ស្ទើរគ្រប់គ្នា។

ខ្មែរគ្រប់រូបមិនអាចបំភ្លេចសិល្បៈរបស់ខ្លួនដែលបង្ហាញអោយគេឃើញពីភាពថ្កុំថ្កើងរុងរឿងកាលពីសម័យបុរាណបានឡើយ ។

មេរៀន ៧៦ : អត្ថបទ

# ភ្លេងនិងរបាំខ្មែរ



ខ្មែរមានភ្លេងនិងរបាំសំរាប់ជនជាតិខ្លួន។ គេលេងភ្លេងកំសាន្តនៅពេលលំហែពីការងារ។ នៅពេលបុណ្យទានម្តងៗគេប្រគំភ្លេង ហើយមានរបាំផង ។

ភ្លេងខ្មែរមានសូររងំ ។ គ្រឿងភ្លេងខ្មែរមានស្គរ សំភោរនោត គង ស្រឡៃ ខ្លុយ ចាប៉ី ទ្រ តាខេ ឃឹម ជាដើម ។

របាំខ្មែរមានភាពរស់រវើក ហើយមានកាយវិការទន់ភ្លន់ ។



មេរៀន ៧៧ : អត្ថបទ

# ប្រាសាទអង្គរ

ប្រាសាទអង្គរជាប្រាសាទដែលខ្មែរបានសាងយ៉ាងល្អវិចិត្រតាំងពីយូរយារណាស់មកហើយ ។ កាលបើគេមើលពីចម្ងាយ គេឃើញកំពូលខ្ពស់ត្រដែត ។

ប្រាសាទនេះសាងឡើងអំពីផ្ទាំងថ្មធំៗបន្តបពីលើគ្នា។ នៅតាមជញ្ជាំងប្រាសាទមានរូបចម្លាក់ក្បូរក្បាច់ល្អក្រៃលែង ។

អ្នកដំណើរមកដល់ទីនេះ បានឃើញហើយតែងកោតស្ញប់ស្ញែងសរសើរដល់ថ្វីដៃខ្មែរជំនាន់នោះ ។



## មេរៀន ៧៨ : រឿងព្រេងខ្មែរ

# កុមារជ័យចាញ់បោកសេដ្ឋី



ថ្ងៃមួយ កុមារជ័យបានរត់លេងក្បែរផ្ទះសេដ្ឋី។ នៅលើផ្ទះ ប្រពន្ធសេដ្ឋីកំពុងត្បាញ។ ពេលនោះ ត្រល់មួយជ្រុះមកក្រោមផ្ទះ។ ប្រពន្ធសេដ្ឋីឃើញកុមារជ័យក៏ហៅ ៖

_"អាជ័យ! រើសត្រល់ឲ្យអ៊ុំបន្តិច" ។

_"អ៊ុំឲ្យអ្វីខ្ញុំ?" កុមារជ័យសួរ ។

_"អ៊ុំឲ្យអំបុក ។

_ តើអ៊ុំឲ្យច្រើនឬតិច ?

_ ច្រើន!"

កុមារជ័យឮថាច្រើនត្រេកអរណាស់ ក៏ស្ទុះទៅរើសត្រល់ជូនប្រពន្ធសេដ្ឋីភ្លាម ។ ប្រពន្ធសេដ្ឋីបានយកអំបុកមួយកញ្ជើមកឲ្យកុមារជ័យ ។

_"ទេ! តិចណាស់អ៊ុំ" ។

កុមារជ័យស្រែកយំ ហើយរាដៃពុំព្រមយក ។ សេដ្ឋីឮកុមារជ័យយំ ក៏ចេញមកសួររឿងហេតុ។ ប្រពន្ធគាត់បានប្រាប់សព្វគ្រប់ សេដ្ឋីងក់ក្បាល ។ គាត់យកចង្អេរមួយមក ហើយក៏លើកកញ្ជើអំបុកចាក់រោយលើចង្អេរទាល់តែពេញ ទើបយកទៅឲ្យកុមារជ័យ ។ កុមារជ័យឃើញអំបុកពេញចង្អេរ ក៏ព្រមទទួលយកទៅ។ វេលាយប់ឡើង កុមារជ័យត្រិះរិះគិតទើបដឹងថា_"អញចាញ់បោកសេដ្ឋីទេតើ" ។

## មេរៀន ៧៩ : រឿងព្រេងខ្មែរ

# កុមារជ័យជល់មាន់ឈ្នះ

មេកន្ទ្រាញម្នាក់ មានមាន់ពូកែជល់ឈ្នះគេជានិច្ច ។ មាន់នោះធំសង្ហា ចំពុះមាំ ខ្នាយស្រួច ។

ថ្ងៃមួយ មេកន្ទ្រាញបានមកដល់ភូមិកុមារជ័យ ហើយប្រកាសថា÷

"នៅថ្ងៃស្អែក បើភូមិនេះគ្មានមាន់ណាមកជល់ឈ្នះមាន់យើងទេ យើងនឹងរឹបអូសយកដីស្រែ និងផលស្រូវទាំងអស់" ។ អ្នកភូមិព្រួយ ហើយភិតភ័យជាខ្លាំង ។

ចំណែកកុមារជ័យឮដូច្នោះ ក៏ត្រិះរិះគិតរួចដើរសំដៅទៅផ្ទះ ចាប់កូនមាន់តូចមកទុកក្នុងទ្រុង ។

ព្រឹកឡើង កុមារជ័យយកមាន់តូចនោះទៅជល់នឹងមាន់របស់មេកន្ទ្រាញ ។ កុមារជ័យសួរថា÷ " យ៉ាងដូចម្ដេចហៅថាឈ្នះ ? " មេកន្ទ្រាញតបថា÷ " មាន់ឈ្នះ ដេញតាមពីក្រោយមាន់ចាញ់ " ។

នៅក្នុងសង្វៀន មាន់ធំឃើញកូនមាន់ក៏នៅស្ងៀម ។ មាន់តូចសសុសចូលក្រោមមាន់ធំទ្រាំថាមេវា មាន់ធំរសើបក៏រត់ទៅ កូនមាន់ចេះតែរត់ដេញតាមពីក្រោយ ។

កុមារជ័យទះដៃស្រែក " ឈ្នះហើយៗ " អ្នកភូមិក៏ទះដៃបន្ទរ " កុមារជ័យជល់មាន់ឈ្នះ " ។



បន្ថែម

# ថ្ងៃខែខ្មែរ

## ថ្ងៃ

១. អាទិត្យ ២. ចន្ទ ៣. អង្គារ ៤. ពុធ

៥. ព្រហស្បតិ៍ ៦. សុក្រ ៧. សៅរ៍

## ខែតាមចន្ទគតិ

| | | |
|---|---|---|
| ១. មិគសិរ | ២. បុស្ស | ៣. មាឃ |
| ៤. ផល្គុន | ៥. ចេត្រ | ៦. ពិសាខ |
| ៧. ជេស្ឋ | ៨. អាសាឍ | ៩. ស្រាពណ៍ |
| ១០. ភទ្របទ | ១១. អស្សុជ | ១២. កត្តិក |

## ខែតាមសុរិយគតិ

| | | |
|---|---|---|
| ១. មករា | ២. កុម្ភៈ | ៣. មិនា |
| ៤. មេសា | ៥. ឧសភា | ៦. មិថុនា |
| ៧. កក្កដា | ៨. សីហា | ៩. កញ្ញា |
| ១០. តុលា | ១១. វិច្ឆិកា | ១២. ធ្នូ |

# ឆ្នាំខ្មែរ



# តារាងអក្សរភ្ជាប់នឹងរូបភាព

